**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ......៣៨៦.........អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១២

# សេចក្តីជូនដំណឹង
## ស្តីពី
## ជំរុញការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១២

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនលោក លោកស្រី ដែលជាម្ចាស់យានយន្តគ្រប់ប្រភេទមេត្តាជ្រាបថា ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ រហូតមកដល់ពេលនេះ មានម្ចាស់យានយន្តគ្រប់ប្រភេទបានអញ្ជើញមកប្រកាសបង់ពន្ធជាបណ្តើរៗតាមសេចក្តីជូនដំណឹងលេខ ០០៦ សហវ.សជណ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ដើម្បីឱ្យការប្រមូលពន្ធសម្រាប់ឆ្នាំ២០១២នេះ ប្រព្រឹត្តទៅបានល្អប្រសើរ បង្ការបានភាពអសកម្មនានា ដែលតែងតែកើតឡើងជាយថាហេតុនាពេលជិតផុតកំណត់នៃកាលបរិច្ឆេទត្រូវបង់ពន្ធនោះ សុំអញ្ជើញម្ចាស់យានយន្តគ្រប់ប្រភេទដែលមិនទាន់បានទៅប្រកាស និងបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ សូមមេត្តារួសរាន់អញ្ជើញទៅបង់ពន្ធនេះ ទៅតាមទីតាំងរបស់រដ្ឋបាលពន្ធដារ ជាអាទិ៍មាន ស្នាក់ការពន្ធដារស្រុក សាខាពន្ធដារខេត្ត និងនៅសាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ ។ ដោយឡែកស្រុក ឬខណ្ឌណាដែលគ្មានស្នាក់ការពន្ធដារស្រុក ឬសាខាពន្ធដារខណ្ឌសូមអញ្ជើញទៅបង់ពន្ធនៅតាមក្រុមការងារនៅក្នុងទីតាំងរដ្ឋបាលសាលាស្រុក-ខណ្ឌ ។

ថ្វីត្បិតកន្លែងប្រមូលពន្ធមានកម្រិតដូចបានជម្រាបជូនខាងលើ តែនៅក្នុងឆ្នាំ២០១២នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពន្លាតរយៈពេលប្រកាសបង់ពន្ធរហូតដល់៥ខែ គឺពីទី១៥ កុម្ភៈ ដល់ ១៥ កក្កដា ដែលឆ្នាំកន្លងទៅមានរយៈពេលតែ៣ខែប៉ុណ្ណោះ ។

ចាប់ពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ តទៅ អង្គភាពពន្ធដារនឹងសហការជាមួយស្ថាប័នមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ ដោយពិន័យបន្ថែមលើប្រាក់ពន្ធស្មើនឹង ១០០ ភាគរយ នៃប្រាក់ពន្ធដែលត្រូវបង់ចំពោះយានយន្តណាដែលមិនបានប្រកាសបង់ពន្ធនេះទាន់ពេលវេលា ។

ដោយហេតុនេះ សូមអស់លោក លោកស្រី ជាម្ចាស់យានយន្តទាំងអស់ មេត្តារួសរាន់អញ្ជើញទៅប្រកាស និងបង់ពន្ធពីដើមដៃឱ្យបានរួចរាល់នៅតាមគោលដៅដូចបានជម្រាបជូនខាងលើ ចៀសវាងការកកកុញប្រជ្រៀតគ្នាបង់ពន្ធនេះនៅពេលចុងកាលបរិច្ឆេទកំណត់ ។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូន លោក លោកស្រី ជាម្ចាស់យានយន្តទាំងអស់ដែលបានបង់ពន្ធនេះសម្រាប់ឆ្នាំ២០១២រួចហើយ សុំមេត្តារក្សាបង្កាន់ដៃពន្ធបញ្ជាក់ការបង់ពន្ធនេះឲ្យបានគត់មត់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យនាពេលខាងមុខ ។

អគ្គនាយកដ្ឋានពន្ធដារមានក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីម្ចាស់យានយន្តទាំងអស់នឹងយកចិត្តទុកដាក់អនុវត្តបានយ៉ាងគាប់ប្រសើរជាពុំខាន ។

**អគ្គនាយកដ្ឋានពន្ធដារ**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708/ Fax: (885) 23 886 700